**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តក្រចេះ**

សំណុំរឿងព្រហ្មទណ្ឌលេខ:៤១៩
ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨

**សាលក្រមព្រហ្មទណ្ឌ**
**លេខ: ២៧១ "ខ"**
ចុះថ្ងៃទី២០ ខែកញ្ញា គ.ស២០១៩

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តក្រចេះ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តក្រចេះ
នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩
និងប្រកាសសាលក្រមនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩
ដោយមានសមាសភាពចូលរួមដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តក្រចេះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តក្រចេះ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តក្រចេះ

**មេធាវី**

លោក [redacted] មេធាវីការពារជនជាប់ចោទ
លោក [redacted] មេធាវីការពារជនជាប់ចោទ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤១៩ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ៖

១/ ឈ្មោះ [redacted] ស្រីភាស់ ភេទស្រី អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែង កំណើត [redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិដូនជ្រាំ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ ឪពុកឈ្មោះ [redacted] សុវណ្ណ (ស) ម្តាយឈ្មោះ [redacted] សុផន (ស) ប្តីឈ្មោះ [redacted] ស៊ីណាក់ កូន០៣នាក់ ទោសពីមុនគ្មាន (ក្នុងឃុំ១៤ .០៦.១៨) ។

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥០ ឃ.ខ១៨ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ ។

**ជាប់ចោទពីបទ៖** ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិដូនជ្រាំ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២/ ឈ្មោះ [redacted] ស៊ីណាក់ ភេទប្រុស អាយុ៤០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរអាវុធហត្ថផ្ទៃប្រទេស ទីកន្លែងកំណើតភូមិ [redacted] ខេត្តក្រចេះ ទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្ត ក្រចេះ ឪពុកឈ្មោះ [redacted] ទុន (ស) ម្តាយឈ្មោះ [redacted] គឹមណាន(រ) ប្រពន្ធឈ្មោះ [redacted] ស្រីភាស់ កូន៣នាក់ ទោស ពីមុនគ្មាន (ក្នុងឃុំ១៤.០៦.២០១៨) ។

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៥១ ឃ.ខ១៨ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ ។

៣/ ឈ្មោះ [redacted] ស៊ីណា ([redacted] ស៊ីណា) ភេទប្រុស អាយុ៣៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបររត់តាក់ស៊ី ទីកន្លែងកំណើតភូមិ[redacted] ខេត្តក្រចេះ ទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តក្រចេះ ឪពុកឈ្មោះ[redacted] ណាត (រ) ម្តាយឈ្មោះ [redacted] ថុន (រ) ប្រពន្ធឈ្មោះ[redacted] ចន្ទ្រា (ម៉ាលី) កូន៣នាក់ ទោសពីមុន គ្មាន (ក្នុងឃុំ០៧.០៨.២០១៨) ។

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៨៧ ឃ.ឌ១៨ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៨ ។

<u>ជាប់ចោទពីបទ៖</u> ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិដូនជ្រាំ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ បទ ល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ៤០,៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

<u>ដើមបណ្តឹងរដ្ឋប្បវេណី៖</u> បណ្តឹងអាជ្ញា។

## បានឃើញ

-ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២៨៨ អ.យ.ក/១៨ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងខេត្តក្រចេះ ។

-ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នរបស់ឈ្មោះ [redacted] ស្រីភាស់ លេខ១៧១៤ ព.ស១៨ ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរ ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនរបស់ឈ្មោះ [redacted] ស្រីភាស់ លេខ១៥០ ឃ.ឌ១៨ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០ ១៨ របស់ចៅក្រមស៊ើបសួរ ។

-ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នរបស់ឈ្មោះ[redacted] ស៊ីណាក់ លេខ១៧១៥ ព.ស១៨ ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរ ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនរបស់ឈ្មោះ[redacted] ស៊ីណាក់ លេខ១៥១ ឃ.ឌ១៨ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០ ១៨ របស់ចៅក្រមស៊ើបសួរ ។

-ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នរបស់ឈ្មោះ[redacted] ស៊ីណា ([redacted] ស៊ីណា) លេខ២៣២១ ព.ស ១៨ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរ ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនរបស់ឈ្មោះ [redacted] ស៊ីណា ([redacted] ស៊ីណា) លេខ១៨៧ ឃ.ឌ១៨ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរ ។

-ដីកាសន្និដ្ឋានស្ថាពរលេខ ៣៤៧ អ.យ.ក/២០១៨ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាដំបូងខេត្តក្រចេះ ។

-ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣១០៩ ព.ស/២០១៨ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០ ១៨ របស់ចៅក្រមស៊ើបសួរ ។

-បានឃើញ លទ្ធផលកោសលវិច័យគ្រឿងញៀនលេខ១៦៤៣៤/១៨ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

-បានឃើញ ពាក្យសុំលើកពេលសវនាការលេខ សឌ០០៥/១៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ របស់មេធាវីការពារសិទ្ធិជនជាប់ចោទ។

-បានឃើញ ពាក្យសុំលើកពេលសវនាការលេខ ០១១សឌ/១៩ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ របស់មេធាវីការពារសិទ្ធិជនជាប់ចោទ។

-បានឃើញ ពាក្យស្នើសុំដាក់កម្មវិធីជំនុំជម្រះក្នុងពេលតែមួយលេខ ០១២សឧ/១៩ ចុះថ្ងៃទី១៣ ខែ មីនា ឆ្នាំ២០១៩ របស់មេធាវីការពារសិទ្ធិជនជាប់ចោទ។

**<u>អង្គហេតុនៃរឿងហេតុមានដូចតទៅ</u>**

កាលថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង១៧ និង០០នាទី ដោយមានការដឹកនាំ និងសម្រប សម្រួលនីតិវិធីផ្ទាល់ពី [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តក្រចេះ កម្លាំងការិយាល័យប្រឆាំងគ្រឿងញៀនបានចុះបង្ក្រាបករណី ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចផ្ទះជនសង្ស័យ ស្ថិតនៅភូមិដូនជ្រាំ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ ឃាត់ខ្លួនបានជនសង្ស័យ ០២នាក់ ឈ្មោះ [redacted] ស៊ីណាក់ ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ និងឈ្មោះ [redacted] ស្រីភាស់ ភេទស្រី អាយុ៣៣ឆ្នាំ និងធ្វើការឆែកឆេរដកហូតបានសម្ភារៈវត្ថុតាងមាន៖ គ្រឿងញៀនប្រភេទ (មេតំហ្វេតាមីន) ICE ចំនួន១កញ្ចប់មធ្យម **ទម្ងន់១,៤៤ក្រាម**, ជញ្ជីងសម្រាប់ថ្លឹង គ្រឿងញៀន០១, សម្ភារៈសម្រាប់ជក់គ្រឿងញៀនមួយចំនួន, ថង់សម្រាប់វែលេកគ្រឿងញៀនមួយចំនួន, កាមេរ៉ាសុវត្ថិភាព និងអេក្រង់កែច្នៃ(EVD)ចំនួន ០១, កុំព្យូទ័រម៉ាកLENNOVO ThinkPad ចំនួន០១គ្រឿង, ទូរសព្ទ ដៃម៉ាកHUA WEI ចំនួន០១គ្រឿង, ទូរសព្ទដៃម៉ាកNOKIA (ពណ៌ខ្មៅ និងពន៌ខៀវ) ចំនួន០២គ្រឿង, ប័ណ្ណ សម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះចំនួន០១, អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចំនួន០២ សន្លឹក ។

**<u>នាពេលសវនាការ</u>**

- ជនជាប់ចោទ ឈ្មោះ [redacted] ស្រីភាស់ បានឆ្លើយថា៖ នៅថ្ងៃកើតហេតុមានប៉ូលីសបានមកឆែកឆេរនៅផ្ទះរបស់នាងខ្ញុំ ដោយឃើញដូចនេះនាងខ្ញុំបានបោះថ្នាំញៀនចោលតាមបង្អួច ដោយប៉ូលីសមិនបានឆែករកឃើញទេ ។ នាងខ្ញុំលួចលក់ថ្នាំញៀនមិនអោយប្ដីដឹងទេ។ ការលក់ថ្នាំញៀននេះនាងខ្ញុំយកលក់អោយគេដោយបោះតាមផ្លូវដោយលក់ម្ដង១ម៉ឺនរៀល នាងខ្ញុំមិនចេះជក់ថ្នាំញៀនទេ ដោយលក់ប៉ុន្មានដងមិនចាំទេ នាងខ្ញុំបានទិញថ្នាំញៀនតាមរយៈទូរសព្ទមិនចាំលេខ និងទៅយកនៅវាលវង់ដោយក្នុងតម្លៃ២៥ម៉ឺនរៀល អ្នកដែលយកថ្នាំមកអោយនាងខ្ញុំមិនចាំមុខទេ។ ប្ដីនាងខ្ញុំមិនបានដឹងថាខ្ញុំលក់ថ្នាំញៀន ហើយគាត់បានហាមឃាត់ខ្ញុំដែរតែខ្ញុំមិនស្ដាប់ ។ នាងខ្ញុំមិនស្គាល់ **ឈ្មោះ** [redacted] ស៊ីណា ទេ។ ពេលប្ដីនាងខ្ញុំចង់ប្រើប្រាស់ នាងខ្ញុំយកថ្នាំរបស់ខ្ញុំអោយគាត់ជក់ ។ សព្វថ្ងៃនាងខ្ញុំមានជំងឺប្រចាំកាយ កើតគីសនៅក្នុងដោះ ហើយនាងខ្ញុំមានកូនតូចៗ៣នាក់ ក្នុងបន្ទុក ហើយសព្វថ្ងៃនេះកូនៗរបស់ខ្ញុំត្រូវអ្នកភូមិយកចិញ្ចឹម។

- ជនជាប់ចោទឈ្មោះ [redacted] ស៊ីណាក់ បានឆ្លើយថា៖ នៅថ្ងៃដែលប៉ូលីសចូលមកឆែកឆេរខ្ញុំបានគេងនៅអង្រឹងក្រោមផ្ទះ ដំបូងមានប៉ូលីសម្នាក់ទេ ក្រោយមកមានច្រើននាក់ ។ កាមេរ៉ាសុវត្ថិភាពដែលមាននៅផ្ទះមិនដំណើរការទេ ខ្ញុំមិនដឹងថាប្រពន្ធខ្ញុំមានថ្នាំញៀនឬអត់ទេ។ ពីមុនខ្ញុំមិនដែលដឹងថាប្រពន្ធខ្ញុំលក់ថ្នាំញៀននោះទេ ហើយថ្មីៗនេះខ្ញុំក៏បានដឹង និងបានហាមឃាត់គាត់ដែរ តែមិនស្ដាប់ខ្ញុំទេ ខ្ញុំមិនដែលស្គាល់ **ឈ្មោះ** [redacted] ស៊ីណា នោះទេ ហើយក៏មិនដែលលក់ថ្នាំញៀនអោយ ឈ្មោះ [redacted] ស៊ីណា ដែរ ។ ខ្ញុំមិនបានឃើញប្រពន្ធខ្ញុំយកថ្នាំបោះចោលទេ ព្រោះប្រពន្ធខ្ញុំនៅក្នុងបន្ទប់ ។ ខ្ញុំទើបចេះប្រើប្រាស់ថ្នាំញៀនថ្មីៗនេះទេ។ ខ្ញុំបាទមិនដឹងប្រពន្ធខ្ញុំបានថ្នាំញៀនពីណាទេ ។

- ជនជាប់ចោទ ឈ្មោះ [redacted] ស៊ីណា (ម៉ុល ស៊ីណា) បានឆ្លើយថា៖ ខ្ញុំបាទស្គាល់ **ឈ្មោះ** [redacted] ស្រីភាស់ និងឈ្មោះ [redacted] ស៊ីណាក់ នេះប្រហែល៣ទៅ៤ខែមកហើយ ព្រោះខ្ញុំទៅយកថ្នាំញៀនពីពួកគាត់បាន ៣,៤ លើកមកហើយ ។ ខ្ញុំមិនដែលយកថ្នាំញៀនពីអ្នកផ្សេងទេ ។ ដោយខ្ញុំទិញថ្នាំញៀនពីគាត់ម្ដងៗកន្លះជ្រុងតម្លៃ

១លានរៀល ។ ពេលខ្ញុំទៅយកថ្នាំពីប្រពន្ធ ឈ្មោះ [redacted] ស្រីភាស់ ពេលនោះប្តី ឈ្មោះ [redacted] ស៊ីណាក់ ក៏នៅទីនោះដែរ ។ ខ្ញុំបាទស្គាល់ពួកគាត់យូរហើយ ។ ខ្ញុំបាទស៊ីឈ្នួលយកថ្នាំញៀនអោយគេ ដោយគេអោយថ្លៃឈ្នួលម្តង ៣ ទៅ ៤ ម៉ឺនរៀល ។ ពេលខ្ញុំទៅយកថ្នាំគឺ នៅផ្ទះរបស់គាត់ ហើយខ្ញុំបានដាក់លុយចោលក្បែរៗនោះ ។

- តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំៈ ក្រោយពីបានស្តាប់ចំលើយជនជាប់ចោទ តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានដូចតទៅ ៖

យល់ឃើញថាៈ ចម្លើយរបស់ជនជាប់ ឈ្មោះ [redacted] ស្រីភាស់ និងចម្លើយឈ្មោះ [redacted] ស៊ីណា [redacted] ស៊ីណា) ដែលបានឆ្លើយនៅអង្គសវនាការនោះ គឺមិនអាចអោយតំណាងអយ្យការជឿបាន ឡើយ ព្រោះជនជាប់ចោទឈ្មោះ [redacted] ស្រីភាស់ បានបដិសេធថាខ្លួនមិនស្គាល់ ឈ្មោះ [redacted] ស៊ីណា ( [redacted] ស៊ី ណា) ទេ ហើយក៏មិនដែលបានអោយថ្នាំញៀនទៅ ឈ្មោះ [redacted] ស៊ីណា ( [redacted] ស៊ីណា)ដែរ ។ ហើយជនជាប់ចោទ ឈ្មោះ [redacted] ស៊ីណាក់ វិញខ្លួនបដិសេធថា ខ្លួនមិនបានជួញដូរថ្នាំញៀនទេ ខ្លួនគ្រាន់តែអ្នកប្រើប្រាស់តែប៉ុណ្ណោះ ។ ចំណែកជនជាប់ចោទ ឈ្មោះ [redacted] ស៊ីណា ( [redacted] ស៊ីណា) បានឆ្លើយថា ខ្លួនពិតជាបានយកថ្នាំញៀន ពី ឈ្មោះ [redacted] ស្រីភាស់ និងឈ្មោះ [redacted] ស៊ីណាក់ នៅផ្ទះរបស់ពួកគាត់ទាំងពីរនាក់មែន ។ ខ្លួនជាអ្នកយកថ្នាំញៀនអោយគេទេ ដោយគេអោយថ្លៃឈ្នួលម្តង៣ទៅ៤ម៉ឺនរៀល ខ្លួនមិន មែនជាអ្នកជួញដូរថ្នាំញៀនទេ ។

យល់ឃើញថាៈ មានពិរុទ្ធភាពលើជនជាប់ចោទ ឈ្មោះ [redacted] ស្រីភាស់ ពីបទជួញ ដូរដោយខុសច្បាប់នូវសារធាតុញៀន ។

យល់ឃើញថាៈ មានពិរុទ្ធភាពលើជនជាប់ចោទ ឈ្មោះ [redacted] ស៊ីណាក់ និងជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ( [redacted] ស៊ីណា) ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។ យោងតាមមាត្រា៤០ និង៤៥ នៃច្បាប់ស្តីការត្រួតពិនិត្យគ្រឿងញៀន បានចែងពីការផ្តន្ទាទោសដាក់ពន្ធនាគារ ២ឆ្នាំ ទៅ៥ឆ្នាំ ។

ហេតុដូច្នេះ តំណាងអយ្យការស្នើសុំទៅចៅក្រមជំនុំជម្រះ ផ្តន្ទាទោសជនជាប់ចោទយ៉ាងតិច៤ឆ្នាំ និងជនចាប់ចោទអាច និង ទទួលទោសពិន័យពី៤លានរៀលទៅ១០លានរៀល ។ សុំបញ្ជូនជនជាប់ចោទ និង សុំណុំរឿងទៅលោកចៅក្រមដើម្បីសម្រេច ។

- សេចក្តីសន្និដ្ឋានមេធាវីៈ ខ្ញុំបាទជាមេធាវីការពារសិទ្ធអោយជនជាប់ចោទ ឈ្មោះ [redacted] ស្រីភាស់ និងជនជាប់ចោទ ឈ្មោះ [redacted] ស៊ីណាក់ សុំធ្វើសេចក្តីសន្និដ្ឋានដូចតទៅៈ

ចំពោះសំណុំរឿង លេខ ៤១៤, ៤១៥, ៤១៦, ៤១៧, ៤១៨ និងសំណុំរឿង លេខ ៤១៩ ឃើញថាអង្គហេតុនៅក្នុសំណុំរឿងទាំង៦នេះ គឺជាអង្គហេតុមួយ ដែលស្ថិតនៅក្នុងអង្គហេតុរបស់សំណុំរឿង លេខ៤១២ ហើយអង្គហេតុទាំងនេះ ខ្ញុំឃើញថា គ្មានភស្តុតាងណាមួយ អាចធ្វើការចោទប្រកាន់ មកលើកូនក្តីរបស់ខ្ញុំដែរ ពីព្រោះកូនក្តីរបស់ខ្ញុំទទួលស្គាល់ហើយ នៅក្នុងសំណុំរឿង លេខ ៤១២ ។ ហើយការចោទប្រកាន់ និងបំបែកសំណុំរឿងរហូតទៅដល់៦រឿងនេះ ខ្ញុំសុំអោយ លោកចៅក្រមមេត្តាពិនិត្យទៅ លើអង្គហេតុនេះ ក្នុងសំណុំរឿង លេខ ៤១៤ ថ្ងៃប្រព្រឹត្តគឺថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ ឃើញថាអង្គហេតុនេះនៅ ក្នុងសំណុំរឿងលេខ ៤១២ ដែលជាអង្គហេតុថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ ដែរ ចឹងជាអង្គហេតុមួយជាន់គ្នា ។ ហើយ ក្នុងសំណុំរឿង លេខ ៤១៥ ជាអង្គហេតុនៅខែមករា ឆ្នាំ២០១៨ ហើយអង្គហេតុក្នុងសំណុំរឿង លេខ ៤១៦ ជាអង្គហេតុខែ កុម្ភៈ ឆ្នាំ ២០១៨ ហើយអង្គហេតុសំណុំរឿង លេខ ៤១៧ ជាអង្គហេតុខែមីនា ឆ្នាំ២០១៨ ក្នុងសំណុំរឿង លេខ ៤១៨ ជាអង្គហេតុខែមេសា ឆ្នាំ២០១៨ សំណុំរឿង លេខ ៤១៩ ជាអង្គហេតុខែឧសភា ឆ្នាំ២០១៨ ចឹងយើងឃើញថា អង្គហេតុទាំងនេះ គឺគ្រាន់តែខុសថ្ងៃប្រព្រឹត្តតែប៉ុណ្ណោះ ប៉ុន្តែលើអង្គហេតុ និងចម្លើយទាំងអស់គឺ មានលក្ខណៈដូចគ្នា



Scanned with CamScanner

ទាំងអស់ ដូចក្នុងសំណុំរឿ លេខ ៤១២ ដូច្នេះខ្ញុំបាទសុំអោយចៅក្រមមេត្តាពិនិត្យទៅលើសំណុំរឿង ទាំងប្រាំមួយរឿងនេះ ហើយ ខ្ញុំសុំអោយសម្រេចបញ្ចូលសំណុំរឿងតែមួយ ឬ សុំសំណុំរឿងទាំងប្រាំមួយនេះ ឲ្យអោយកូនក្ដីខ្ញុំរួចផុតពីបទចោទ ។

- តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានតប៖ ខ្ញុំធ្វើសេចក្ដីសន្និដ្ឋានតបដូចតទៅ ចំពោះនៅក្នុងសំណុំរឿង នីមួយៗ គឺជាអង្គហេតុប្រព្រឹត្តនៅថ្ងៃខុសៗគ្នា ហើយការទិញថ្នាំញៀនក៏ជាថ្ងៃផ្សេងៗគ្នាដែរ ហេតុនេះហើយ ទើបតំណាងអយ្យការធ្វើការបំបែកសំណុំរឿងផ្សេងៗគ្នា ដូចនេះតំណាងអយ្យការសុំរក្សាបទចោទនៅដដែល ហើយក្នុងសំណុំរឿងនីមួយៗ តំណាងអយ្យការស្នើសុំអោយលោកចៅក្រមពិនិត្យមើល និងសម្រេចផ្ដន្ទាទោសលើជនជាប់ចោទ ។ ដោយសារជនជាប់ ឈ្មោះ [redacted] ស៊ីណា [redacted] ស៊ីណា) បានឆ្លើយថា យកថ្នាំញៀនច្រើនដង ច្រើនសារ ពីជនជាប់ចោទ ឈ្មោះ [redacted] ស្រីភាស់ និងឈ្មោះ [redacted] ស៊ីណាក់ គឺនៅថ្ងៃខុសគ្នា ខែខុសគ្នា តែឆ្នាំតែមួយ ទើបតំណាងអយ្យការបំបែកសំណុំរឿង និងតំណាងអយ្យការរក្សាបទចោទដដែល ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានាដែលពាក់ព័ន្ធនឹងសំណុំរឿង

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់

## **តុលាការខេត្តក្រចេះ**

## **យល់ឃើញថា**

១/ កាលថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង១៧ និង០០នាទី ពិតជាមានអង្គហេតុដែល មានការដឹកនាំ និងសម្រប សម្រួលនីតិវិធីផ្ទាល់ពី លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តក្រចេះ កម្លាំងការិយាល័យ ប្រឆាំងគ្រឿងញៀនបានចុះបង្ក្រាបករណី ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុច ផ្ទះជនសង្ស័យ ស្ថិតនៅភូមិដូនជ្រាំ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ ឃាត់ខ្លួនបានជនសង្ស័យ ០២នាក់ ឈ្មោះ [redacted] ស៊ីណាក់ ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ និងឈ្មោះ [redacted] ស្រីភាស់ ភេទស្រី អាយុ៣៣ឆ្នាំ និងធ្វើការឆែកឆេរដកហូតបានសម្ភារៈវត្ថុតាងមាន៖ គ្រឿងញៀនប្រភេទ (មេតំហ្វេតាមីន) ICE ចំនួន១កញ្ចាប់មធ្យម ទម្ងន់១,៤៤ក្រាម, ជញ្ជីងសម្រាប់ថ្លឹង គ្រឿងញៀន០១, សម្ភារៈសម្រាប់ជក់គ្រឿងញៀនមួយចំនួន, ថង់សម្រាប់វែកគ្រឿងញៀនមួយចំនួន, កាំម៉េ រ៉ាសុវត្ថិភាព និងអេក្រង់កែច្នៃ(EVD)ចំនួន០១, កុំព្យូទ័រម៉ាកLENNOVO ThinkPad ចំនួន០១គ្រឿង, ទូរសព្ទ ដៃម៉ាកHUA WEI ចំនួន០១គ្រឿង, ទូរសព្ទដៃម៉ាក NOKIA (ពណ៌ខ្មៅ និងពន៍ខៀវ) ចំនួន០២គ្រឿង, ប័ណ្ណ សម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះចំនួន០១, អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចំនួន០២ សន្លឹក ។

២/ អង្គហេតុ និងសកម្មភាពរបស់ជនជាប់ចោទ ដែលបានប្រព្រឹត្តនៅចំណុច ភូមិដូនជ្រាំ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង១៧ និង០០នាទី ខាងលើនេះ គឺជាបទល្មើសព្រហ្មទណ្ឌ ដែលតម្រូវឲ្យផ្ដន្ទាទោសពីបទ៖ ជួញដូរ និងប្រើប្រាស់ ដោយខុសច្បាប់នូវសារធាតុញៀន ស្របតាម មាត្រា៤០, មាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

ប៉ុន្តែ អង្គហេតុដែលបានចោទប្រកាន់ក្នុងសំណុំរឿងនេះ គឺជាអង្គហេតុដែលចោទប្រកាន់តាមចម្លើយរបស់ជនជាប់ចោទ ឈ្មោះ [redacted] ស៊ីណា ។ ជនជាប់ចោទ ឈ្មោះ [redacted] ស៊ីណា ([redacted] ស៊ីណា) បានឆ្លើយ



Scanned with CamScanner

ថា៖ ខ្លួនស្គាល់ ឈ្មោះ [redacted] ស្រីភាស់ និងឈ្មោះ [redacted] ស៊ីណាក់ ប្រហែល ៣ទៅ៤ខែ មកហើយ ព្រោះខ្លួនទៅយកថ្នាំញៀនពីពួកគាត់ បាន៣ទី៤លើកមកហើយ ដោយខ្លួនទិញថ្នាំ ញៀនម្តងៗកន្លះជ្រុងតម្លៃ១លានរៀល ។

តុលាការបានសម្រេចផ្តន្ទាទោស ជនជាប់ចោទឈ្មោះ [redacted] ស្រីភាស់ និងជនជាប់ចោទឈ្មោះ [redacted] ស៊ីណាក់ ក្នុងអង្គហេតុនេះ និង២អង្គហេតុផ្សេងទៀត (សំណុំរឿងលេខ ៤១២, ៤១៤, ៤១៥) តាមចម្លើយសារភាពរបស់ជនជាប់ចោទ ឈ្មោះ [redacted] ស៊ីណា ([redacted] ស៊ីណា) នេះរួចហើយ ហេតុដូច្នេះ បញ្ជាក់ឲ្យឃើញថា គ្មានភស្តុតាងណាមួយ ដែលបញ្ជាក់ឲ្យឃើញពីអង្គហេតុ នៃការប្រព្រឹត្តិបទល្មើសដែលបានចោទប្រកាន់ក្នុងសំណុំរឿងនេះទេ (សំណុំរឿងលេខ ៤១៦) គប្បីតុលាការពិនិត្យ និងសម្រេចតាមនីតិវិធីច្បាប់ ។

៣/ ជនជាប់ចោទ ឈ្មោះ [redacted] ស្រីភាស់ បានឆ្លើយថា នៅថ្ងៃកើតហេតុ មានប៉ូលីសបានមកឆែកឆេរនៅផ្ទះរបស់ខ្លួន ដោយឃើញដូចនេះ ខ្លួនបានបោះថ្នាំញៀនចោលតាមបង្អួច ។ ការលក់ថ្នាំញៀននេះ ខ្លួនយកលក់អោយគេ ដោយបោះតាមផ្លូវ ដោយលក់ម្តង ១ម៉ឺនរៀល ។ ខ្លួនមិនចេះជក់ថ្នាំញៀនទេ ។ ខ្លួនបាន ទិញថ្នាំញៀនតាមរយៈទូរសព្ទមិនចាំលេខ និងទៅយកនៅវាលវង់ ដោយក្នុងតម្លៃ២៥ម៉ឺន រៀល អ្នកដែលយកថ្នាំមកអោយខ្លួនមិនចាំមុខទេ ។ គប្បីតុលាការពិនិត្យ និងសម្រេចតាមនីតិវិធីច្បាប់ ។

៤/ ជនជាប់ចោទ ឈ្មោះ [redacted] ស៊ីណាក់ បានឆ្លើយថា៖ ខ្លួនមិនដឹងថាប្រពន្ធខ្លួនមានថ្នាំញៀនឬអត់ទេ ។ ពីមុនខ្លួនមិនដែលដឹងថា ប្រពន្ធខ្លួនលក់ថ្នាំញៀននោះទេ ហើយថ្មីៗនេះខ្លួនក៏បានដឹង និងបានហាមឃាត់គាត់ដែរ តែមិនស្តាប់ខ្លួនទេ ។ ខ្លួនមិនដឹងប្រពន្ធខ្លួនបានថ្នាំញៀនពីណាទេ។ ខ្លួនមិនដែលស្គាល់ ឈ្មោះ [redacted] ស៊ីណា នោះទេ ហើយក៏មិនដែលលក់ថ្នាំញៀនអោយ ឈ្មោះ [redacted] ស៊ីណា ដែរ ។ ខ្លួនទើបចេះប្រើប្រាស់ថ្នាំញៀនថ្មីៗនេះទេ ។ គប្បីតុលាការពិនិត្យ និងសម្រេចតាមនីតិវិធីច្បាប់ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

ក- អោយជនជាប់ចោទ៖

១. ឈ្មោះ [redacted] ស្រីភាស់ (ដែលមានសាវតាជាតិដូចខាងលើ)

រួចផុតពីបទចោទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ស្របតាមមាត្រា ៤០នៃច្បាបស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលបានប្រព្រឹត្តនៅភូមិដូនជ្រាំ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ កាលពីអំឡុង ខែមិថុនា ឆ្នាំ២០១៨ ។

ខ- អោយជនជាប់ចោទ៖

១. ឈ្មោះ [redacted] ស៊ីណាក់ (ដែលមានសាវតាជាតិដូចខាងលើ)

២. ឈ្មោះ [redacted] ស៊ីណា (ដែលមានសាវតាជាតិដូចខាងលើ)

រួចផុតពីបទចោទ ជួញដូរ និងប្រើប្រាស់ ដោយខុសច្បាប់នូវសារធាតុញៀន ស្របតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាបស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលបានប្រព្រឹត្តនៅភូមិដូនជ្រាំ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ កាលពីអំឡុង ខែមិថុនា ឆ្នាំ២០១៨ ។



Scanned with CamScanner

សាលក្រមនេះ ជំនុំជម្រះ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ថ្ងៃសុក្រ ៧រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ក្រចេះ, ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩

**ក្រឡាបញ្ជីសវនាការ**

**ហត្ថលេខា និងត្រា** [redacted]

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា** [redacted]

---

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

សាលក្រមនេះបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ.....សុក្រ.....៥ កើត.....ខែ.....កត្តិក.....ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ក្រចេះ,ថ្ងៃទី.....០១.....ខែ.....វិច្ឆិកា.....គ.ស ២០១៩

**ក្រឡាបញ្ជី**

[redacted]